ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

# តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ ភ្នំពេញ

សំណុំរឿង **រដ្ឋប្បវេណី**
**លេខៈ ០៧០**
ចុះថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ ២០១៨
**សាលដីកា**
**លេខៈ ១២** ក្រ.វ "ប.ស"
ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៨

បានបើក និង បញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២៤ ខែ កក្កដា ឆ្នាំ២០១៨ ។

**សមាសភាពក្រុមប្រឹក្សា**

លោក [redacted] ប្រធានក្រុមប្រឹក្សា
លោក [redacted] ចៅក្រុមប្រឹក្សា
លោកស្រី [redacted] ចៅក្រុមប្រឹក្សា

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

-ដើមចោទឈ្មោះ [redacted] ស៊ីហ្វែរ ភេទស្រី អាយុ៦៥ឆ្នាំ ជាតិខ្មែរ ជានាយិកាក្រុមហ៊ុន [redacted] ទីលំនៅបច្ចុប្បន្នផ្ទះលេខៈ [redacted] ។

-ចុងចម្លើយឈ្មោះ [redacted] សុវ៉ាត ភេទប្រុស អាយុ ៤៥ឆ្នាំ ទីលំនៅ [redacted] ។

**<u>កម្មវត្ថុបណ្តឹង:</u>** -ប្តឹងសុំឲ្យតុលាការចេញសាលក្រមៈ

១-រំលាយកិច្ចព្រមព្រៀង ចុះថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ។

២-ទាមទារប្រាក់ពីចុងចម្លើយចំនួន៩៥.២៧៨,៤$(ប្រាំបួនម៉ឺនប្រាំពាន់ពីររយចិតសិបប្រាំបីដុល្លារអាមេរិក និងបួនសេន) ។

៣-ទាមទារប្រាក់សំណងជម្ងឺចិត្ត ការខាតបង់ពេលវេលា និងការចំណាយលើសេវាកម្មច្បាប់សរុបចំនួន ៥០.០០០$ (ប្រាំម៉ឺនដុល្លារអាមេរិក)។

-ស្នើរសុំលក់ឡៃឡុងទ្រព្យជានាបំណុល ដែលមានទីតាំងនៅភូមិក្រឡាញ់ ឃុំក្បាលត្រាច ស្រុកក្រគរ ខេត្តពោធិ៍សាត់ ដែលមានទំហំ៥៤.៩០៥ម$^2$(ប្រាំម៉ឺនបួនពាន់ប្រាំបួនរយប្រាំ)ម៉ែត្រការ៉េ មានវិញ្ញាបនបត្រសម្គាល់អចលនវត្ថុលេខ:150307-0862 ចុះថ្ងៃទី ០៣-១២-២០១២។

-ការចំណាយលើប្រាក់ប្រដាប់ក្តី និងប្រាក់ពន្ធផ្សេងៗ ជាបន្ទុកភាគីចុងចម្លើយ ។

-ស្នើសុំឲ្យមានការអនុវត្តន៍បណ្តោះអាសន្នលើសាលក្រមនេះ។

## អំពីអង្គហេតុ និងចំណុចវិវាទ

-តាមពាក្យបណ្តឹងចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ២០១៦ ឈ្មោះ [redacted] ស៊ីវហ៊ួរ នៅក្នុងកំឡុងខែតុលា ឆ្នាំ២០១២ ឈ្មោះ [redacted] សុវ៉ាត ជាចុងចម្លើយ បានមកទាក់ទង ក្រុមហ៊ុនរបស់ដើមចោទដែលមានឈ្មោះ [redacted] ដើម្បីប្រមូលទិញត្រីប្រម៉ាផ្គត់ផ្គង់ក្រុមហ៊ុនរបស់នាងខ្ញុំៗដោយមានជំនឿចិត្តលើការព្រមព្រៀងនេះ នាងខ្ញុំបានប្រគល់ប្រាក់ឱ្យឈ្មោះ [redacted] សុវ៉ាត ចំនួន ០២លើក សរុបស្មើនឹងចំនួន ១០០.០០០$(មួយសែនដុល្លារអាមេរិក)។ ក្រោយពីទទួលបានប្រាក់គ្រប់ចំនួនហើយឈ្មោះ [redacted] សុវ៉ាត បែរជាគេចវេស មិនព្រមគោរពតាមការព្រមព្រៀងគ្នាឡើយដែលជាហេតុធ្វើឱ្យនាងខ្ញុំទទួលរង នូវការខូចខាតយ៉ាងធ្ងន់ធ្ងរៗរហូតដល់ថ្ងៃទី ២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ទើបនាងខ្ញុំអាចទាក់ទងជាមួយឈ្មោះ [redacted] សុវ៉ាត និងបានចុះកិច្ចសន្យាព្រមព្រៀងជាមួយគ្នា ក្នុងការទូទាត់ប្រាក់ ដែលឈ្មោះ [redacted] សុវ៉ាត បានទទួលពីនាងខ្ញុំសរុបចុងក្រោយមានចំនួន ៩៥.២៧៨,៤$ (ប្រាំបួនម៉ឺន ប្រាំពាន់ពីររយចិតសិបប្រាំបីដុល្លារអាមេរិកនិងបួនសេន)។ដោយឈ្មោះ [redacted] សុវ៉ាត បានយកដីមួយកន្លែង ដែលមានទីតាំងនៅភូមិក្រឡាញ់ឃុំក្បាលត្រាចស្រុកក្រគរខេត្តពោធិ៍សាត់ ទំហំ៤៥.៩០៥ម២ដែលមានវិញ្ញាបនបត្រសំគាល់ម្ចាស់អចលវត្ថុលេខ: 150307-0862 ចុះថ្ងៃទី ០៣-១២-២០១២ ដើម្បីជានាលើប្រាក់ដែលមិនទាន់បានទូរទាត់មកឱ្យនាងខ្ញុំ ។ ប៉ុន្តែក្រោយពីបានចុះកិច្ចព្រមព្រៀងនេះឈ្មោះ [redacted] សុវ៉ាត នៅតែគេចវេសមិនព្រមធ្វើការទូទាត់ឡើយ រហូតមកដល់ បច្ចុប្បន្ន។

-បានឃើញ សាលក្រមរដ្ឋប្បវេណីចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ដែលមានខ្លឹមសារដូចតទៅ:

១-ច្រានចោលបណ្តឹងតបរបស់ចុងចម្លើយលោក [redacted] សុវ៉ាត ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៦។

២-រំលាយកិច្ចព្រមព្រៀងរវាងដើមចោទ និងចុងចម្លើយ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៣ ត្រង់ចំណុចប្រការ ៣ ។

៣-ឲ្យចុងចម្លើយលោក [redacted] សុវ៉ាត សងប្រាក់ទៅដើមចោទអ្នកស្រី [redacted] ស៊ីវហ៊ួរ ជានាយិកាក្រុមហ៊ុន [redacted] ចំនួន ៩៥.២៧៨,៤$ (ប្រាំបួនម៉ឺនប្រាំពាន់ពីរ រយចិតសិបប្រាំបីដុល្លារអាមេរិកនិងបួនសេន) ការទាមទារលើសពីនេះច្រានចោល។

៤-ឱ្យអនុវត្តសាលក្រមនេះជាបណ្តោះអាសន្ន ត្រង់ចំណុចលេខ "៣" នៃសាលក្រមនេះ តាមមត្រា ១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី

៦-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ភាគីចុងចម្លើយតាមមាត្រា·៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី

-បានឃើញ សេចក្តីចម្លងបណ្តឹងឧទ្ធរណ៍លេខ:២៦ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] សុវ៉ាត ប្តឹងឧទ្ធរណ៍នឹងសាលក្រមរដ្ឋប្បវេណីចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៦ របស់

សាលាដំបូងខេត្តពោធិ៍សាត់ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

**ដំណាក់កាលទាញហេតុផលដោយផ្ទាល់មាត់**

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ស៊ីវហួរ (អវត្តមាន)

-មេធាវី: លោក [redacted] (វត្តមាន)

-ចុងចម្លើយឈ្មោះ [redacted] សុំាត (អវត្តមាន)

-មេធាវី: លោក [redacted] (អវត្តមាន)

ប្រធានក្រុមប្រឹក្សាអានរបាយការណ៍សង្ខេបអង្គហេតុ:

-ចុងចម្លើយឈ្មោះ [redacted] សុំាត (អវត្តមាន)

**សេចក្តីថ្លែងការណ៍របស់មេធាវីចុងចម្លើយ**

-មេធាវី: លោក [redacted] តំណាងដោយអាណត្តិឱ្យចុងចម្លើយឈ្មោះ [redacted] សុំាត" (អវត្តមាន) ចូលខ្លួនមុនពេលដំណើរការនីតិវិធី ប៉ុន្តែចាកចេញវិញ មិនចូលរួមនីតិវិធី ដោយពុំមានហេតុផល ។

**សេចក្តីថ្លែងការណ៍របស់មេធាវីដើមចោទ**

-មេធាវី: លោក [redacted] (តំណាងដោយអាណត្តិឱ្យដើមចោទឈ្មោះ [redacted] ស៊ីវហួរ ) បានថ្លែងការណ៍ថា:ឈ្មោះ [redacted] សុំាត បានធ្វើកិច្ចសន្យាព្រមព្រៀងថា បានទទួលសស្គាល់ការប្រគល់ប្រាក់មកឱ្យកូនក្តីខ្ញុំ តែក្រោយមកឈ្មោះ [redacted] សុំាត បានគេចខ្លួនរហូត។នៅក្នុងនីតិវិធីត្រៀមទាញហេតុផល ក៏ឈ្មោះ [redacted] សុំាត នេះក៏មិនព្រមចូលខ្លួនដែរ ។

សំណូមពរ: តម្កល់សាលក្រមរបស់សាលាដំបូងទុកជាបានការ ។

**សំអាងហេតុ**

សាលាឧទ្ធរណ៍យល់ឃើញថា

១-ពាក្យបណ្តឹងឧទ្ធរណ៍លេខ: ៨៦ ចុះថ្ងៃទី២៨-១១-២០១៦ របស់ឈ្មោះ [redacted] សុំាត ប្តឹងឧទ្ធរណ៍ និងសាលក្រមរដ្ឋប្បវេណី ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៦ ត្រង់ចំណុចសេចក្តីសម្រេចបញ្ចប់ ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ២៦២ ក្រមនីតិវិធីរដ្ឋប្បវេណីសាលាឧទ្ធរណ៍ ទទួលចាត់ការតាមនីតិវិធី ។

២-តាមសេចក្តីថ្លែងការណ៍ របស់មេធាវីតំណាងដោយអាណត្តិឱ្យឈ្មោះ [redacted] ស៊ីវហួរ បានបញ្ជាក់ថា ចុងចម្លើយបានមកទាក់ទងក្រុមហ៊ុន ដើម្បីដើរប្រមូលទិញត្រីប្រមា ហើយខាងក្រុមហ៊ុនបានប្រគល់ប្រាក់ឱ្យចុងចម្លើយចំនួន ១០០.០០០$ "មួយរយពាន់ដុល្លារអាមេរិក" តែក្រោយពេលទទួលបានប្រាក់ បែរជាមិនបានអនុវត្តតាមកិច្ចសន្យានោះទេ។ដើមចោទនិងចុងចម្លើយបានទូទាត់គ្នាឃើញថា ប្រាក់ដែលចុងចម្លើយ នៅជំពាក់ប្រាក់ដើមចោទចំនួន ៩៥.២៧៨,៤$។

សំណូមពរ: សុំតម្កល់សាលក្រមសាលាដំបូងទុកជាបានការ ។

៣-លោក ថន ឫទ្ធី ជាមេធាវីតំណាងដោយអាណត្តិឱ្យចុងចម្លើយ (អវត្តមាន) បានចូលមកក្នុងបន្ទប់សវនាការបានបន្តិចក៏ចាកចេញទៅវិញ ដោយពុំមានមូលហេតុអ្វីបញ្ជាក់ទេ ក្រុមប្រឹក្សាសម្រេចដំណើរការនីតិវិធីបន្ត។

៤-ក្រុមប្រឹក្សាយល់ឃើញថា តាមកិច្ចព្រមព្រៀងចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ២០១៣ បញ្ជាក់ថា ចុងចម្លើយពិតជាទទួលស្គាល់ថា ខ្លួននៅជំពាក់ប្រាក់ដើមចោទចំនួន ៩៥.២៧៨,៤$ ពិតមែន ហើយប្រាក់នេះ ចុងចម្លើយក៏ពុំទាន់បានសងទៅដើមចោទដែរ។ ដូច្នេះគប្បីចុងចម្លើយសងប្រាក់នេះទៅដើមចោទវិញ។

៥-តុលាការសាលាដំបូងខេត្តពោធិ៍សាត់ បានលើកយកសំអាងហេតុបញ្ជាក់មានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ ហើយសាលាឧទ្ធរណ៍ឯកភាពលើសំអាងហេតុនោះ ដោយពុំចាំបាច់សរសេរសំអាងហេតុដដែលនោះបញ្ជាក់សារជាថ្មី។

សេចក្តីសម្រេច នៃសាលក្រមរដ្ឋប្បវេណីចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៦ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ គប្បីតម្កល់ទុកជាបានការដដែល ។

**<u>សេចក្តីសម្រេចបញ្ចប់</u>**

១-ច្រានចោលបណ្តឹងឧទ្ធរណ៍លេខ: ២៦ ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ២០១៦ របស់ឈ្មោះ [redacted] ស៊ុរ៉ាត ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីចុះថ្ងៃទី ១៧ ខែតុលា ឆ្នាំ២០១៦ របស់សាលាដំបូងខេត្តពោធិ៍សាត់ ទុកជាបានការ។

៣-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ឈ្មោះ [redacted] ស៊ុរ៉ាត។

-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៩ ខែ សីហា ឆ្នាំ២០១៨ បើកផ្លូវប្តឹងសាទុក្ខរយៈពេល ០១ខែ គិតចាប់តាំងពីថ្ងៃបានទទួលការបញ្ជូនសាលដីកា ។

| **ក្រឡាបញ្ជី** | **ចៅក្រមប្រឹក្សា** | **ប្រធានក្រុមប្រឹក្សា** |
|---|---|---|
| *ហត្ថលេខា* | *ហត្ថលេខា* | *ហត្ថលេខា* |

[redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញថ្ងៃទី ០៧ ខែ ០៩ ឆ្នាំ២០១៨

**ក្រឡាបញ្ជី**

បានឃើញ

**ប្រធានក្រុមប្រឹក្សា**

[redacted]

[redacted]